# តើវាអាចជាការពុលមេតាណុល?

## 1 រោគសញ្ញា

0–12ម៉ោង (ឬលើសពីនេះ បើមានផឹក Ethanol លាយជាមួយ)

### មានប្រវត្តិផឹកគ្រឿងស្រវឹង?

តើអ្នកជំងឺបានផឹកស្រាដែលផលិតខុសច្បាប់ ឬ ចូលរួមផឹកជាមួយអ្នកដែលសង្ស័យថាពុល មេតាណុលឬអត់?



12–24ម៉ោង (ឬលើសពីនេះ បើមានផឹក Ethanol លាយជាមួយ)



### មានអារម្មណ៍ឈឺក្បាលធីងធោង(អាការៈស្រវឹង)?

មានអារម្មណ៍មិនស្រួលខ្លួន ក្អួត ចង្អោរ។



### ឈឺទ្រូង ឬ រោគសញ្ញាក្រពះពោះវៀន?

ឈឺទ្រូងខ្លាំង និង រោគសញ្ញាក្រពះពោះវៀន ឈឺពោះ។



### មានដង្ហើមញ៉ាប់/ដង្ហក់

លើសពី 25 ដង /មួយនាទី។



### ការរំខាននៃការមើលឃើញ

រាល់ការរំខាននៃការមើលឃើញគ្រប់ប្រភេទ, រាប់ចាប់តាំងពីការស្រវាំងភ្នែករហូតដល់មើលមិនឃើញទាំងស្រុង។

24–48ម៉ោង (ឬលើសពីនេះ បើមានផឹក Ethanol លាយជាមួយ)

### សន្លប់ បាត់ស្មារតី



## 2 ការព្យាបាល

**A** បើអ្នកជំងឺគ្មានរោគសញ្ញា:
បន្តតាមដាន (សូមមើលរោគសញ្ញានៅខាងក្រោម ខាងឆ្វេង)។

**B** មានដង្ហើមញ៉ាប់/ដង្ហក់ ប៉ុន្តែគ្មានការរំខាននៃការមើលឃើញ:
ឲ្យអេតាណុល និង ប៊ីកាបូណាត។តាមដានបន្តយ៉ាងតិច 24ម៉ោង។

**C** មានដង្ហើមញ៉ាប់/ដង្ហក់ និង ការរំខាននៃការមើលឃើញ
ឲ្យអេតាណុល និង ប៊ីកាបូណាត folinic (or folic) acid, ពិចារណាបញ្ជូនទៅកាន់កន្លែងលាងឈាម។

**D** មានដង្ហើមញ៉ាប់/ដង្ហក់ និង សន្លប់បាត់ស្មារតី:
ឲ្យអេតាណុល និង ប៊ីកាបូណាត folinic (or folic) acid, បញ្ជូនទៅកាន់កន្លែងលាងឈាម។

**E** ដង្ហើមធម្មតា ឬ ដង្ហើមខ្សោយ (ដកដង្ហើមមួយៗ)
សន្លប់បាត់ស្មារតី: អាចជាការពុលមេតាណុលធ្ងន់ធ្ងរ ត្រូវប្រុងប្រយ័ត្នវាអាចច្រលំជាមួយការពុល ethanol លើកលែងតែមានការជឿជាក់ច្បាស់ថាជាមេតាណុលពិតមែន។ឲ្យប៊ីកាបូណាត folinic (or folic) acid, ពិចារណាបញ្ជូនទៅមន្ទីពេទ្យបង្អែក។

## 3 កំរិតប្រើប្រាស់

**ផ្តល់ប៊ីការបូណាត** (Bicarbonate $NaHCO_3$):

- 500 mmol/L: ប្រើចំណុះ 250 -500 mL ឬ ច្រើនជាងហ្នឹង អំឡុង 1 – 2 ម៉ោង រហូតដល់ ការដកដង្ហើមញ៉ាប់ ត្រលប់មករកសភាពធម្មតាវិញ (ចង្វាក់ដង្ហើម <20 ដងក្នុង១នាទី)។
- 167 mmol/L: ប្រើចំណុះ 1000 - 1500 mL រឺ ច្រើនជាងហ្នឹង អំឡុង 1 – 2 ម៉ោង រហូតដល់ការដកដង្ហើមញ៉ាប់ មករកភាពធម្មតាវិញ (ចង្វាក់ដង្ហើម <20 ដងក្នុង១នាទី)។
- **ប្រសិនបើមានថ្នាំគ្រាប់ប៊ីការបូណាត៖** ប្រើថ្នាំគ្រាប់ប៊ីការបូណាតកំរិត 500mg (ស្មើរនឹង 6mmol) អាចប្រើពី 6 – 10 គ្រាប់រៀងរាល់ម៉ោង រហូតដល់ចង្វាក់ដង្ហើមត្រលប់មករកសភាពធម្មតាវិញ (ចង្វាក់ដង្ហើម <20 ដងក្នុង១នាទី)។

**អាស៊ីត Folinic (រឺ អាស៊ីត folic)** : ចាក់តាមសរសៃចំណុះ 50mg រឺ ប្រើថ្នាំគ្រាប់ (ឧ៖ 10 គ្រាប់ដែល មួយគ្រាប់មាន 5mg) រៀងរាល់ 6ម៉ោង ម្តង រយៈពេល 24 – 48 ម៉ោង។ **ប្រសិនបើចាំបាច់ត្រូវធ្វើការ សុងផ្លូវដង្ហើម (Intube)** : អ្នកជំងឺត្រូវបញ្ចូលខ្យល់ (ចង្វាក់ដង្ហើម > 25ដងក្នុងមួយនាទី) (រហូតដល់បញ្ជូនទៅដល់ផ្នែកសង្គ្រោះបន្ទាន់ (ICU)។ឲ្យ antidote (ethanol តាមមាត់ ឬ តាមសរសៃ) ដោយមិនរង់ចាំ។ សូមមើលកំរិតប្រើប្រាស់នៅខាងក្រោម។

| ETHANOL: | 5 % ETHANOL (beer) | 10 % ETHANOL (wine) | 20 % ETHANOL (fortified wine) | 40 % ETHANOL (spirits) |
|---|---|---|---|---|
| **កំរិតចាប់ផ្តើម** (Loading) | 15 mL/គីឡូ | 7.5 mL/គីឡូ | 4 mL/គីឡូ | 2 mL/គីឡូ |
| **កំរិតផឹក / ម៉ោង** (អ្នកផឹកម្តងម្កាល) | 2 mL/គីឡូ/ម៉ោង | 1 mL/គីឡូ/ម៉ោង | 0.5 mL/គីឡូ/ម៉ោង | 0.25 mL/គីឡូ/ម៉ោង |
| **កំរិតផឹក / ម៉ោង** (អ្នកប្រមឹកស្រា) | 4 mL/គីឡូ/ម៉ោង | 2 mL/គីឡូ/ម៉ោង | 1 mL/គីឡូ/ម៉ោង | 0.5 mL/គីឡូ/ម៉ោង |

English_Kenya_version1_April_2016_simplified




មេតាណុលគឺមិនបានបង្កឲ្យពុលដោយផ្ទាល់ទេ ប៉ុន្តែបន្ទាប់ពីមេតាបូលីស វាបង្កឲ្យមានការពុលកំរិតខ្ពស់ តាមទំរង់ Formic Acid។ការព្យាបាលគឺត្រូវទប់ស្កាត់អង់ហ្ស៊ីម (ADH) និងថ្នាំបន្សាប(antidote) (ethanol) ដើម្បីទប់ស្កាត់មេតាបូលីសអាស៊ីតដូហ្សីស និង ប៊ីការបូណាត បើអាចទៅរួចប្រើវិធីលាងឈាម ដើម្បីបញ្ចេញចោលនូវ មេតាណុល និង formate ហើយកែតំរូវមេតាបូលីសអាស៊ីតដូហ្សីស។ គួរផ្តល់ Folinic acid ដើម្បីជំរុញមេតាបូលីស formate។

**តើពេលណាដែលអ្នកគួរស្វែងរកជំនួយ:**

បើមានអ្នកជំងឺដែលសង្ស័យខ្លាំងថាពុលមេតាណុល សូមទាក់ទងតាមទូរស័ព្ទទៅកាន់មន្ទីពេទ្យបង្អែក ឬ ទាក់ទងទៅកាន់ការិយាល័យគ្រូពេទ្យគ្មានព្រំដែនតាមរយៈ លេខទូរស័ព្ទ .......... ឬ .......... សំរាប់ជំបូន្មាន និងពិភាក្សានៅអន្តរាគមន៍ដែលអាចធ្វើបាន។ហេតុផលមួយដែលសំខាន់ជាងគេគឺរកឲ្យឃើញថាមានការពុលស្រាកំពុងកើតឡើង ដើម្បីចាប់ផ្តើមការព្យាបាល និងជូនដំណឹងទៅដល់សាធារណៈជនអំពីគ្រោះថ្នាក់ដែលអាចកើតមាន។

**បើមានករណីពុលទីមួយកើតឡើង ជានិច្ចជាកាលតែងតែមានករណីពុលជាបន្តបន្ទាប់**

Oslo University Hospital

www.methanolpoisoninginitiative.com

MEDECINS SANS FRONTIERES
DOCTORS WITHOUT BORDERS